# ការបង្ហាញពីរបៀបចុះឈ្មោះសំរាប់គេហទំព័រមាតាបិតានៃសង្កាត់សាលារៀនអូកឡិនដ៍

| | |
|---|---|
| ដើម្បីបង្កើតគណនីថ្មីមួយបាន សូមទៅកាន់គេហទំព័រ https://parent.ousd.org រួចចុចលើតំណ Create New Account |  |
| | |
| សូមចុចជ្រើសរើសប្រភេទគណនី |  |
| | |
| សូមបញ្ចូល និងពិនិត្យផ្ទៀងផ្ទាត់លើអាសយដ្ឋានអ៊ីមែល និងពាក្យសម្ងាត់ |  |

លោកអ្នកនឹងទទួលបាននូវអ៊ីមែលបញ្ជាក់មួយច្បាប់ ពី ssoadmin@ousd.k12.ca.us។

| | |
|---|---|
| អ៊ីមែលបញ្ជាក់អំពីការចុះឈ្មោះបង្កើតគណនី | ថ្ងៃខែ និងពេលវេលា<br><br>សូមថ្លែងអំណរអរគុណលោកអ្នកចំពោះការចុះឈ្មោះបង្កើតគណនី Aeries។ ដើម្បីឱ្យប្រាកដថាគណនីនេះ ពិតជាត្រូវស្នើសុំបង្កើតដោយលោកអ្នកនោះ សូមចុចលើតំណាងសមស្របនៅខាងក្រោមនេះ ឬក៏ចុចចម្លង រួចបិទភ្ជាប់ URL (អាសយដ្ឋានអ៊ិនធឺណិត) នៅត្រង់កន្លែងបញ្ចូលអាសយដ្ឋានអ៊ិនធឺណិតនៃកម្មវិធីរុករករបស់លោកអ្នក។<br><br>បើសិនជាលោកអ្នកអាចធ្វើបាន សូមចុចតំណានានាដូចតទៅនេះ ដើម្បីធ្វើការបញ្ជាក់ ឬដើម្បីធ្វើការបដិសេធចោលនូវគណនីនេះ៖<br><br>បញ្ជាក់អាសយដ្ឋានអ៊ីមែលនេះ<br><br>ច្រានចោលអាសយដ្ឋាននេះ<br><br>បើសិនជាលោកអ្នកមិនអាចចុចលើតំណានានាខាងលើបានទេនោះ លោកអ្នកត្រូវការចុចចម្លង រួចបិទភ្ជាប់ URL ដូចតទៅនេះ ដាក់ចូលទៅក្នុងកន្លែងបញ្ចូលអាសយដ្ឋាននៃកម្មវិធីរុករកតាមអ៊ិនធឺណិតរបស់លោកអ្នក។<br><br>http://10.128.34.241/ConfirmEmail.aspx<br><br>លោកអ្នក បន្ទាប់មក នឹងត្រូវបានណែនាំតាមរយៈអេក្រង់កំព្យូទ័រនូវព័ត៌មានដូចតទៅនេះ ដែលលោកអ្នកអាចចុចចម្លង និងបិទភ្ជាប់ទៅក្នុងទំព័រ៖<br><br>អាសយដ្ឋានអ៊ីមែល៖ អាសយដ្ឋានអ៊ីមែលរបស់លោកអ្នកប្រើប្រាស់<br><br>ពាក្យសម្ងាត់សំរាប់អ៊ីមែល៖ **QPPDU2C85JV9EA6HBG54** |

| | |
|---|---|
| បន្ទាប់ពីការបញ្ជាក់អំពីអាសយដ្ឋានអ៊ីមែលរបស់លោកអ្នកមក លោកអ្នកត្រូវការបញ្ចូលព័ត៌មានដូចតទៅនេះ ដើម្បីតភ្ជាប់គណនីប្រចាំគេហទំព័ររបស់លោកអ្នកទៅនឹងព័ត៌មានអំពីកូនលោកអ្នក។<br><br>បើសិនជាលោកអ្នកពុំឃើញមានព័ត៌មាននេះទេនោះ សូមទាក់ទងសាលារៀនរបស់កូនលោកអ្នក ដើម្បីព័ត៌មាននេះ។ | <br> |
| សូមជ្រើសរើសទំនាក់ទំនងដែលបញ្ជាក់ថាលោកអ្នកត្រូវជាអ្វីចំពោះកូនសិស្ស ឬ ជ្រើសរើសយក None of the above | <br> |
| | |
| | លោកអ្នក ឥឡូវនេះ អាចចូលក្នុងគេហទំព័រមាតាបិតាបានហើយ។ |
| | |

លោកអ្នកអាចបញ្ចូលកូន លោកអ្នកបានថែមទៀតទៅ ក្នុង គណនីរបស់លោកអ្នក តាមការចុចលើប៊ូតុង change student បន្ទាប់មកចុចលើ តំណ add additional student។

